# មេរៀនទី ១៤១: ព្រះមានព្រះបន្ទូលទៅអេលីយ៉ាដោយសម្លេងតូចរហៀងៗ

## ១ ពង្សាវតាក្សត្រ ១៩:៩-១៨

**គោលបំណង៖** ព្រះលើកទឹកចិត្តយើង។

**ខគម្ពីរចងចាំ៖ យ៉ូស្វេ១:៩** *“តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះកុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់គង់ជាមួយនៅកន្លែងណាដែលឯងទៅផង។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលព្រះយេស៊ូវដឹកនាំជីវិតយើង យើងមិនដែលនៅម្នាក់ឯងទេ។ សូម្បីតែពេលយើងបាក់ទឹកចិត្ត ឬឯកោក៏ដោយ យើងអាចជួបជាមួយនឹងវត្តមានរបស់ទ្រង់ ដោយការគាំទ្រ និងការលើកទឹកចិត្តពីគ្រិស្តបរិស័ទផ្សេងទៀត។ សូមគិតអំពីពេលវេលាដែលអ្នកមានអារម្មណ៍ថា ត្រូវបានបោះបង់ចោលដោយព្រះ ឬដោយមនុស្ស។ តើអ្នកបានទទួលកម្លាំងពីព្រះ ឬពីមិត្តភក្តិក្នុងអំឡុងពេលពិបាកចិត្តដែរឬទេ? ដូចអេលីយ៉ាដែរ យើងតែងតែទទួលបានការគាំទ្រពីព្រះជាទីស្រឡាញ់របស់យើង។ តើអ្នកនឹងផ្តល់កម្លាំងចិត្តដល់មិត្តភក្តិ ដែលជួបការលំបាកក្នុងសប្តាហ៍នេះដោយរបៀបណា?

**ចំរៀង៖** ១.ព្រះយេស៊ូវគឺជាព្រះអម្ចាស់ ២.ចូរមានកំលាំងនិងចិត្តក្លាហានចុះ ៣.ខ្ញុំអាចធ្វើគ្រប់ការ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ៣. ល្បែងកំសាន្ត «គ្មានបញ្ហា»

**សម្ភារៈដែលត្រូវការ៖** ប៉េងប៉ោង ឧបសគ្គ(កំណាត់ឈើ ឬអំបោស)



១. ចែកកុមារជាពីរក្រុម ហើយឲ្យពួកគេចាប់ដៃគូរពីរៗនាក់។

២. ឲ្យប៉េងប៉ោងមួយទៅក្រុមទាំងពីរ ហើយឲ្យពួកគេដាក់ប៉េងប៉ោងនៅចន្លោះខ្នងរបស់ពួកគេ ហើយដើរទៅកាន់ទីជាមួយគ្នា។



៣. ដាក់ឧបសគ្គនៅលើឥដ្ឋ ដើម្បីឲ្យកុមារលោតរំលង។

៤. ប្រសិនបើពួកគេធ្វើឲ្យធ្លាក់ប៉េងប៉ោងនោះពួកគេត្រូវចាប់ផ្តើមម្តងទៀត។

៥. លេងល្បែងនេះរហូតដល់កុមារនៅក្នុងក្រុមទាំងពីរបានលេងគ្រប់គ្នា។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះតែងតែមានវត្តមាននៅក្នុងជីវិតរបស់យើង ដូច្នេះយើងត្រូវបានលើកទឹកចិត្តដោយព្រះ និងបន្តដំណើររបស់យើងទោះបីជាយើងបរាជ័យក៏ដោយ។ គ្មានអ្វីអាចរារាំងយើងបានទេ ព្រោះព្រះតែងតែលើកទឹកចិត្តដល់យើង!

## ៤. ការណែនាំមេរៀន

នៅថ្ងៃនេះអ្នកគ្រូចង់ឲ្យប្អូនធ្វើទឹកមុខតាមអ្នកគ្រូទាំងអស់គ្នា បើគ្រូធ្វើមុខក្រៀមក្រំ ប្អូនត្រូវធ្វើមុខក្រៀមក្រំទាំងអស់គ្នា បើគ្រូធ្វើមុខសើចយើងសើចទាំងអស់គ្នា ហាស់ៗៗ...... គ្រូធ្វើមុខយំ យើងធ្វើសំលេងយំទាំងអស់គ្នាហ៊ឺៗ...... ពេលគ្រូធ្វើខឹង យើងធ្វើខឹងទាំងអស់គ្នាដោយសំឡក់ដាក់គ្នា គ្រូធ្វើមុខសប្បាយ យើងត្រូវរាំទាំងអស់គ្នា។

តើអ្នកនឹងធ្វើដូចម្តេចនៅពេលដែលអ្នកមានការក្រៀមក្រំ? តើអ្នកនឹងយំឬ? តើអ្នកនឹងខឹងឬ? ឬក៏អ្នកនឹងស្វែងរកនរណាម្នាក់ដើម្បីលើកទឹកចិត្តអ្នកឬ? ព្រះបានចាត់មនុស្សជាច្រើនមកក្នុងជីវិតរស់នៅរបស់យើង ដើម្បីលើកទឹកចិត្តយើង។ ថ្ងៃនេះយើងហ្នឹងរៀនពីបុរសម្នាក់ ដែលមានការសោកសៅនៅតែម្នាក់ឯង និងពីរបៀបដែលព្រះលើកទឹកចិត្តដល់គាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះ ដកស្រង់ចេញពីព្រះគម្ពីរ **១ ពង្សាវតាក្សត្រ**។ មនុស្សម្នាមានការខឹងសម្បាជាមួយនឹងអេលីយ៉ា។ អេលីយ៉ាមានអារម្មណ៍ថាឯកា និងនៅតែឯង។ អេលីយ៉ាបានធ្វើដំណើរ៤០ថ្ងៃ ៤០យប់ដើម្បីទៅដល់ភ្នំហោរែបជាភ្នំនៃព្រះ។ លុះមកដល់ភ្នំហើយគាត់ក៏លូនចូលរូងភ្នំដើម្បីសម្រាក។

បន្ទាប់មកគាត់ក៏លឺព្រះបន្ទូលនៃព្រះ "អេលីយ៉ាអើយ តើធ្វើអីនៅទីនេះ?" អេលីយ៉ាបានប្រាប់ព្រះថា គាត់បានបម្រើព្រះដោយអស់ពីចិត្ត និងស្មោះត្រង់ ប៉ុន្តែជនជាតិអ៊ីស្រាអែលនៅតែបំផ្លាញអាសនា ដែលពួកគេគោរពប្រណិប័តន៍ព្រះ ហើយថែមទាំងបានសម្លាប់ហោររបស់ព្រះទៀតផង។ គាត់បានប្រាប់ព្រះថាគាត់ជាហោរតែម្នាក់គត់ដែលនៅសេសសល់ ហើយពួកគេក៏ចង់សម្លាប់គាត់ដែរ។ ព្រះក៏មានបន្ទូលថា **១ ពង្សាវតាក្សត្រ១៩:១១** "ចូរឯងចេញទៅឈរលើភ្នំនៅចំពោះព្រះយេហូវ៉ាចុះ នោះមើល ព្រះយេហូវ៉ាទ្រង់យាងទៅតាមទីនោះ។"

ពេលនោះមានខ្យល់បក់ខ្លាំងរហូតធ្វើឲ្យថ្មភ្នំបាក់បែកជាដុំៗ។ ប៉ុន្តែ ព្រះមិននៅក្នុងខ្យល់ទេ។ បន្ទាប់មក ការរញ្ជួយដីដ៏ខ្លាំងកក្រើកដី។ ប៉ុន្តែព្រះមិននៅក្នុងការរញ្ជួយដីនោះទេ។ បន្ទាប់មកអណ្តាតភ្លើងដ៏សន្ធោសន្ធៅមួយបានឆាបឆេះលើភ្នំ។ ប៉ុន្តែព្រះមិននៅក្នុងភ្លើងទេ។ ចុងក្រោយមានសំឡេងតូចរហៀងៗមួយបានមកដល់។ ព្រះទ្រង់គង់នៅក្នុងសម្លេងតូចរហៀងៗនោះ។ សម្លេងតូចរហៀងៗនោះបានលើកទឹកចិត្តដល់អេលីយ៉ា។ ព្រះបានប្រាប់អេលីយ៉ាថា ឯងមិននៅតែឯងទេ គឺមានមនុស្ស៧ពាន់នាក់ ដែលនៅតែស្រលាញ់ព្រះ។ ព្រះអង្គក៏បានប្រាប់អេលីយ៉ាពីអ្វីដែលគាត់ត្រូវធ្វើ នៅពេលដែលគាត់ត្រឡប់ទៅរកប្រជាជនអ៊ីស្រាអែលវិញ។ ព្រះបន្ទូលនៃព្រះ គឺពិតជាលើកទឹកចិត្តដល់លោកអេលីយ៉ាខ្លាំងណាស់។

នៅពេលដែលអេលីយ៉ាបាក់ទឹកចិត្ត ព្រះទ្រង់មិនបានមកដោយខ្យល់បក់គំហុក ការរញ្ជួយដី ឬក៏អណ្តាតភ្លើងឆាបឆេះនោះទេ។ ព្រះបានយាងមកកាន់អេលីយ៉ាតាមរយៈសម្លេងតូចរហៀងៗ ស្រាលស្រទន់ក្នុងការនិយាយលើកទឹកចិត្តមកកាន់អេលីយ៉ា។

ព្រះក៏លើកទឹកចិត្តយើងនៅពេលដែលយើងមានការភ័យខ្លាច មានជម្ងឺ ឯកា ឬក៏ពេលយើងត្រូវការជំនួយ។ ពេលខ្លះព្រះបានលើកទឹកចិត្តយើងតាមរយៈអ្នកដែលនៅជុំវិញយើង។ ព្រះអាចលើកទឹកចិត្តយើងតាមរយៈឪពុកម្តាយរបស់យើង មិត្តភក្តិរបស់យើង គ្រូបង្រៀនរបស់យើង ឬក៏អ្នកជិតខាងរបស់យើងផងដែរ។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាជនជាតិអ៊ីស្រាអែលចង់សម្លាប់ហោរាអេលីយ៉ា? *ពីព្រោះគាត់ជាអ្នកបម្រើរបស់ព្រះ*

២. តើមានហេតុការណ៍អ្វីខ្លះកើតឡើងមុនពេលសម្លេងតូចរហៀងៗ? *ខ្យល់បក់ ការរញ្ជួយដី ភ្លើងឆេះ*

៣. តើព្រះបានមានបន្ទូលទៅកាន់អេលីយ៉ាដោយរបៀបណា? *សម្លេងតូចរហៀងៗ*

៤. តើព្រះបានលើកទឹកចិត្តយើងនៅពេលណាខ្លះ?

*ភ័យខ្លាច មានជម្ងឺ ឯកា ឬក៏ពេលយើងត្រូវការជំនួយ។ល។*

៥. តើអ្នកអាចលើកទឹកចិត្តអ្នកដទៃបានដោយរបៀបណា? *ធ្វើល្អ លើកទឹកចិត្ត និងឱប។ល។*

## ៧. ល្បែងកំសាន្ត «X / O»



**សម្ភារៈដែលត្រូវការ៖** កៅអី ៩

១. ចែកកុមារជាពីរក្រុមស្មើគ្នា។

២. ដាក់កៅអីជា៣ជួរ (គម្លាត១ម៉ែត្រពីគ្នា។)

៣. កុមារត្រូវឈរចម្ងាយ ៣ម៉ែត្រពីកៅអី។

៤. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទាំងអស់ត្រូវរត់ទៅអង្គុយលើកៅអីនោះ។

៥. ក្រុមណាដែលអាចអង្គុយជា "X/O" បានមុន ពួកគេនឹងឈ្នះល្បែងនេះ។ ក្រុមដែលឈ្នះនឹងលើកទឹកចិត្តដល់ក្រុមដែលចាញ់ដោយនិយាយបាក្យថា "អ្នកធ្វើបានល្អហើយ"។

៦. បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់ៗគ្នាបានលេងល្បែងនេះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាព្រះដែលទ្រង់តែងតែលើកទឹកចិត្តដល់យើង ដូច្នេះយើងត្រូវចេះលើកចិត្តដល់គ្នាទៅវិញទៅមកដែរ។

## ៨. ខគម្ពីរចងចាំ យ៉ូស្វេ ១:៩

## ៩. ហាត្ថកម្ម «តើព្រះមានបន្ទូលទៅកាន់អេលីយ៉ាដោយរបៀបណា?»




**សម្ភារៈដែលត្រូវការ៖** ក្រដាសហត្ថកម្ម និងកូល័រ

១. សូមព្រីនក្រដាសហត្ថកម្មនៅទំព័រខាងក្រោម សម្រាប់កុមារគ្រប់ៗគ្នា។

២. ឲ្យកុមារផាត់ពណ៌លើរូបភាពទាំងនោះ។

៣. នៅពេលដែលកុមារផាត់ពណ៌រួច សូមឲ្យកុមារគូររង្វង់ជុំវិញរបៀប ដែលព្រះមានបន្ទូលមកកាន់អេលីយ៉ា។ កុមារគ្រប់គ្នាត្រូវគូសរង្វង់ជុំវិញពាក្យ "សម្លេងតូចរហៀងៗ"។

៤. សូមពន្យល់កុមារថា ព្រះតែងតែលើកទឹកចិត្តដល់យើង។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*

# តើព្រះមានបន្ទូលទៅកាន់អេលីយ៉ាដោយរបៀបណា?

ខ្យល់បក់គំហុក ?



ការរញ្ជួយដី ?



អណ្ដាតភ្លើង ?



សម្លេងតូចរហៀងៗ ?

